E1/420.1/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សំណើសុំការកែតម្រូវ

# Request for Correction

# Demande de Rectificatif

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jun-2016, 10:48
CMS/CFO: Sann Rada

**សំណុំរឿងលេខ (Case/ Dossier):** ០០២/១៩-០៩-២០០៧-

| កែលើឯកសារលេខ:<br>To Document No(s):<br>Cote des documents à rectifier : | ERN(s): | កាលបរិច្ឆេទ:<br>Request Date: | ប្រភេទកំណែ:<br>Correction Type:<br>Type de Correction: |
|---|---|---|---|
| E1/420.1 | 01247269<br>01247274<br>01247278 | ថ្ងៃទី១៥<br>ខែមិថុនា<br>ឆ្នាំ២០១៦ | ☒ កែលើឯកសារដើម<br>Change to Original<br>Correction à apporter à l'original<br>☐ កែលើឯកសារបកប្រែ<br>Change to Translation<br>Correction à apporter à la traduction<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ<br>Reclassification<br>Nouveau classement |

**មូលហេតុនៃការកែតម្រូវ (Reason for changes/ Explications):**

យោងតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យកែប្រែលេខឯកសារលេខ E3/9753 [E3/10577]

**សេចក្ដីលម្អិតនៃការកែតម្រូវ (Details/ Détails):**

កែតម្រូវនៅទំព័រ២៦ បន្ទាត់ទី៥, ទំព័រ៣១ បន្ទាត់ទី១៥ និងទំព័រ៣៥ បន្ទាត់ទី២៣។

ភាគីស្នើសុំ: លី សុផល
**Filing Party/ Déposé par:**

ហត្ថលេខា
**Signature:**

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម):
**Approved by Greffier (for originals):**
**Approuvé par le greffier (pour les originaux) :**

ហត្ថលេខា
**Signature:**

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ):
**Approved by ITU (for translations):**
**Approuvé par le Groupe d'interprétation et de traduction (pour la traduction) :**

ហត្ថលេខា:
**Signature:**

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ មុនពេលសម្រាក ខ្ញុំសូមការបំភ្លឺ ដើម្បីជាកំណត់ត្រាប្រតិចារឹក។ សៀវភៅដែលយើងខ្ញុំប្រកាសទទួលយកអង្គាល់ម្សិលមិញ គឺសៀវភៅរបស់លោក ញ៉ែម អេន នេះ ដែលមានចំណងជើងថា "អ្នកថតរូប<ខ្មែរក្រហម>នៅមន្ទីរស-២១" ឥឡូវដាក់លេខកូដ E3/9753 [E3/10577] បាទនេះជាលេខឯកសារ ដែលយើងកំណត់យក។

**ប្រធានអង្គជំនុំ៖**

សម្រាកចុះ!

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៤ នាទី ដល់ម៉ោង ១០:២៩ នាទី)*

[១០:២៩:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានការឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

មុននឹងបន្ត ខ្ញុំសូមកែប្រែមួយចំនួន។ អ៊ីចឹង ខ្ញុំសូមពេលវេលាបន្ថែមបន្តិច លោកប្រធាន ពីព្រោះថាម្សិលមិញនោះ គឺថាយើងមានសុទិដ្ឋិនិយម គឺថាត្រូវពេលវេលាតិច។ គឺថាឥឡូវ ខ្ញុំសូមរយៈពេល២០

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើកនិយាយអំពីឯកសារមួយដែល<ដកស្រង់ដោយសហព្រះរាជអាជ្ញា ហើយវាស៊ីគ្នាទៅនឹងសៀវ-ភៅ> កំណត់<ហេតុ>ដែលលោកបានផ្ដល់ឱ្យតុលាការ គឺឯកសារD108/3/15.2។ ជាដំបូងខ្ញុំសូមសួរលោក ថាតើលោកបាននាំយកកំណត់ត្រានេះទៅជាមួយដែរឬទេនៅពេលដែលលោករត់ចេញពីមន្ទីរស-២១នោះ?

**ឆ៖** បាទ ខ្ញុំបាទបានធ្វើដំណើរទៅយកបានតែសៀវភៅមួយក្បាលគត់ និង(ឮមិនច្បាស់) តែប៉ុណ្ណឹង បាទអត់មានអីទេ ព្រោះសៀវភៅមួយតូចខ្ញុំអាចស្ពាយបាន តូច សៀវភៅបច្ចេកទេសខ្ញុំ ដែលខ្ញុំរក្សាមកទុកមកទល់សព្វថ្ងៃនេះ អត់មានអីក្រៅពីសៀវភៅមួយក្បាលហ្នឹងទេបាទ។

**ស៖** អ៊ីចឹងគឺនៅឆ្នាំ១៩៧៩ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ។ ឆ្លើយ។

**លោក ញ៉ែម អេន៖**

**ឆ៖** ជាការត្រឹមត្រូវលោកស្រី។

[១០:៤៣:៣៥]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** នៅក្នុងសៀវភៅរបស់លោកគឺឯកសារ E3/9753 [E3/10577] នៅទំព័រ<២៨> លោកបាននិយាយអំពីការរៀនសូត្រនៅប្រទេសចិនរបស់លោក។ លោកបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស៖ “ខ្ញុំចាប់ផ្ដើមរៀនថតរូប ថតវីដេអូនៅ<ខែមករា>ឆ្នាំ៧៦ <នៅអាយុ១៤ឆ្នាំជាមួយក្មេងៗ១៣នាក់មក>ពីប្រទេស<សង្គមនិយម>ផ្សេងៗទៀត។<នៅក្នុង>ថ្នាក់<គ្រូបានបង្រៀនយើង>អំពីជំនាញថត រួមបញ្ចូលទាំងការថតរូបភាព <ការថតរូបមនុស្សពាក់កណ្ដាលខ្លួន ការថត>ខ្សែភាពយន្ត <ការបញ្ចាំងវីដេអូ> ហើយនិងគូរផែនទី” សូមបញ្ចប់ការដកស្រង់។ លោកបានទៅរៀននៅប្រទេសចិន លោកនិយាយថាមានក្មេង១៣នាក់ដែលមកពីប្រទេសសង្គមនិយមផ្សេងៗគ្នា។ អ៊ីចឹងសំណួរខ្ញុំ ចង់សួរថាតើលោករៀននៅពេលនោះហ្នឹង លោករៀនជាភាសាអីដែរ?

**ឆ៖** បាទ លោកស្រីការរៀននោះ គឺរៀនជាភាសាខ្មែរតែម្ដង ហើយមាននិយាយភាសាចិន ប៉ុន្តែគេបកចេញជាភាសាខ្មែរ បាទអត់មានរៀនភាសាចិនផង ខ្ញុំយកៗភាសាខ្មែរ គេបង្ហាត់ជាភាសាខ្មែរ បកឱ្យជាភាសាខ្មែរទាំងអស់។

Deleted:

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ លោកស្រី។ ជារឿងពិត ក្រោយពីសេដ្ឋកិច្ចធ្លាក់ ឬក៏បញ្ហាទាក់ទងហិរញ្ញវត្ថុមក ខ្ញុំបាទខាតច្រើនជិត ២លានដុល្លារដែរនៅអន្លង់វែង អ៊ីចឹងខ្ញុំរកពេលទៅអត់រួចទៅ ក៏ខ្ញុំប្រកាសលក់មែន។ តម្លៃស្បែកជើង អ៊ំ ប៉ុល ពត មួយគូ បាទខ្ញុំលក់ ៥០.០០០ដុល្លារ និងសម្ភារៈរួមទាំងអស់ខ្ញុំកាត់តម្លៃ ១លានដុល្លារ។ នេះជាការពិតមែនបាទ។

**ស៖** នៅក្នុងសំណុំរឿងយើងនោះ យើងមានឯកសារមួយដែលមាន<>ឧបសម្ព័ន្ធ<ពីរ>នៃសំណើរបស់ក្រុម នួន ជា គឺ E398.1.1*(ស៊ុក)* ហើយមានលេខកូដមួយទៀតគឺថា E319/42.3.5 *(ស៊ុក)* ឯកសារតែមួយទេតែមានលេខកូដពីរ។ នៅក្នុងឯកសារនេះ យើង -- បាទ ERNជាភាសាអង់គ្លេសតែមួយទេ អត់មានជាភាសាផ្សេងទៀតទេ គឺ 00987285 តាមឯកសារនេះ <>បង្ហាញថាលោក -- ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេសតែម្តងដើម្បីកុំឲ្យខុសខ្លឹមសារ៖ “លោក ញ៉ែម ស្នាក់ស្ទើរក្នុងគោលគំនិតដែលត្រូវបានកោះហៅដោយ អ.វ.ត.ក ប្រសិនបើមិនមានការផ្តល់លុយឧបត្ថម្ភបន្ថែមទាក់ទងទៅនឹងព័ត៌មានដែលគាត់មាននោះទេ។ គាត់និយាយថា នៅពេលដែលគាត់មកផ្តល់សក្ខីកម្មនៅក្នុងតុលាការនៅក្នុងសំណុំរឿង០០១ គឺថាមិនមានការផ្តល់កម្រៃអ្វីចំពោះគាត់ទាល់តែសោះ។” បាទសូមបញ្ចប់ការដកស្រង់។ នេះជាអ្វីដែលលោកបានលើកឡើងនៅខែឧសភា ឆ្នាំ២០១៤។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកពិតជាបាននិយាយយ៉ាងដូច្នេះមែនទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវ ពេលវេលាខ្ញុំច្រើន ខ្ញុំធ្វើជាចៅហ្វាយស្រុកផង ហើយពេលវេលាមកកម្រៃវាបន្តិចបន្តួចខ្ញុំមក ខ្ញុំទាមទារ បាទ ខ្ញុំទាមទារមែន ដោយសារអី ដោយសារខ្ញុំខាតពេលវេលាផងប្រាក់កម្រៃតិចនេះ ជាការពិត។

[១០:៥៧:២៣]

**ស៖** តាមចម្លើយរបស់លោកនោះ នៅពេលដែលលោកឆ្លើយទៅលោកប្រធានទាក់ទងទៅនឹងមុខងាររបស់លោកសព្វថ្ងៃនេះ<>លោកនិយាយថា លោកបានលាលែងពីតំណែងជាមន្ត្រីរដ្ឋការរបស់លោក ហើយការងារតែមួយរបស់លោកនៅសព្វថ្ងៃនេះ បើតាមចម្លើយរបស់លោកនោះ លោកឆ្លើយថាគឺការបង្កើតក្រុមហ៊ុនមួយដើម្បីលក់សៀវភៅរបស់លោក សៀវភៅដែលលោកផ្តល់មកឲ្យយើងនេះ គឺឯកសារ E3/9753 [E3/10577] ហើយអ៊ីចឹង <តើ>ខ្ញុំ<យល់>លោក<ត្រឹមត្រូវទេ នៅពេលដែលលោកនិយាយ>ថា <នេះជាមុខ>របរ<ចាំបាច់>របស់លោក<ដើម្បីរកស៊ីចិញ្ចឹមជីវិតនៅពេលបច្ចុប្បន្ននេះ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*